**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់ឱ្យបានជ្រាបថា នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ សារព័ត៌មាន Bangkok Post បានចេញផ្សាយអំពីគ្រោះទឹកជំនន់នៅខេត្តឈៀងរ៉ៃ នៃប្រទេសថៃ ដែលបណ្តាលឱ្យមានផលប៉ះពាល់នៅតំបន់ទំនាប ជាពិសេសស្រុកម៉ែសៃ ខេត្តឈៀងរ៉ៃ។ រាជរដ្ឋាភិបាលថៃ បាននិងកំពុងពង្រាយទូកបាតសំប៉ែតដែលបានមកពីស្ថានីយចំនួន ៣ ក្នុងខេត្តឈៀងរ៉ៃ ដើម្បីជម្លៀសជនរងគ្រោះដោយទឹកជំនន់ ដែលភាគច្រើនជាមនុស្សចាស់ ស្ត្រី និងកុមារ។ មកដល់ព្រឹកថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៤ មិនទាន់ទទួលបានព័ត៌មានថាមានពលករកម្ពុជារងគ្រោះ ឬមានបញ្ហាដោយគ្រោះទឹកជំនន់នេះនៅឡើយ។

ក្រសួងបាននិងកំពុងយកចិត្តទុកដាក់តាមដានស្ថានការណ៍វិវត្តន៍នៃគ្រោះទឹកជំនន់នេះ ដោយបានធ្វើការយ៉ាងជិតស្និទ្ធជាមួយស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ និងទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ ដើម្បីធានាថាពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងខេត្តឈៀងរ៉ៃ ទទួលបានការយកចិត្តទុកដាក់ និងស្ថិតនៅទីកន្លែងសុវត្ថិភាព។

ក្រសួងសូមអំពាវនាវដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងខេត្តឈៀងរ៉ៃ និងបណ្តាខេត្តផ្សេងៗទៀត សូមបង្កើនការប្រុងប្រយ័ត្នខ្ពស់ និងបន្តយកចិត្តទុកដាក់តាមដានស្ថានការណ៍ ព្រមទាំងអនុវត្តតាមការណែនាំរបស់អាជ្ញាធរថៃ។

ក្នុងករណីទទួលរងផលប៉ះពាល់ ឬទទួលបានព័ត៌មានអំពីពលករកម្ពុជាដែលរងផលប៉ះពាល់ សូមទំនាក់ទំនងអនុព័ន្ធការងារ (Facebook Page: https://www.facebook.com/la.in.thailand ឬ ទូរសព្ទលេខ ០៩៤ ០៩២ ៥៩០៥ ឬ ០៩៤ ៤១៦ ៥៥១៨) ឬ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ទូរសព្ទលេខ ០៩២ ៨០៥០ ៥៦១ ឬ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ប្រព័ន្ធ Hotline លេខ ១២៨៦ ឬ ១២៩៧ ឬទូរសព្ទលេខ +៨៥៥ ៩៧ ៩២០ ២០២៣) ឬក្រុមតេលេក្រាម "សម្រាប់ពលករទេសន្តរប្រវេសន៍" (https://t.me/KhmerMigrantWorker) ដែលអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃជ្រាបជាព័ត៌មាន។

ថ្ងៃសៅរ៍ ១២កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៤

ប្រព័ន្ធ Telegram

"សម្រាប់ពលករទេសន្តរប្រវេសន៍"